# ការពូកិច្ចដោយសាមគ្គីភាព

ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ២០១៧

ជំនាញការ JICA  MAEDA YUTA

# និយមន័យនៃ
# កាតព្វកិច្ចដោយសាមគ្គីភាព

# និយមន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

**【កាតព្វកិច្ចទូទៅ】**

B ត្រូវសងប្រាក់ទៅ A ចំនួន5000$

**A** ⟶ **B**

(ម្ចាស់បំណុល) (កូនបំណុល)

C ត្រូវសងប្រាក់ទៅ A ចំនួន5000$

**A** ⟶ **C**

※A អាចយកប្រាក់ត្រឹមតែ 5000$ ប៉ុណ្ណោះពី B និង C។

# និយមន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

## 【កាតព្វកិច្ចដោយសាមគ្គីភាព】




B និង C ត្រូវសងប្រាក់រួមចំនួន 10,000$ ទៅ A។

(ម្ចាស់បំណុល)　　(កូនបំណុល)

※A យកប្រាក់ទាំងអស់ពី Bឬ Cក៏បាន
ឬ យកប្រាក់ខ្លះ B ផង និង Cផងក៏បាន។

---

មាត្រា ៩២១

(1)ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ឬ ឲ្យកូនបំណុលទាំងអស់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់។

(2)ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចទាំងអស់ ឬ កូនបំណុលណាម្នាក់ ត្រូវបានប្រកាសក្ស័យធន ម្ចាស់បំណុលអាចចូលរួម ក្នុងការចែកចំណែកនៅក្នុងនីតិវិធីក្ស័យធនរបស់កូនបំណុលនីមួយៗ ចំពោះចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលរបស់ខ្លួន។

# និយមន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

【កាតព្វកិច្ចដោយសាមគ្គីភាព】




ត្រូវសងប្រាក់រួមចំនួន 10,000$ ទៅ A។

①A អាចទាមទារប្រាក់ 10000$ តែចំពោះ B ក៏បាន ឬទាមទារត្រឹមតែ 5000$ ក៏បាន។ ② ហើយ A អាចទាមទារប្រាក់ចំនួន 10000 $ ពី B និង C ស្របពេលជាមួយគ្នាក៏បាន ឬទាមទារតែ 5000$ ពីម្នាក់ៗ ក៏បាន។ ③លើសពីនេះ A អាចទាមទារប្រាក់ចំនួន 10000 $ ពី B បន្ទាប់មក ទាមទារ 5000$ ពី C ទៀតក៏បាន។ ប៉ុន្តែ នៅពេលដែលប្រាក់ត្រូវបានសងសរុប 10000$ កាតព្វកិច្ចនឹងត្រូវរលត់ មានន័យថា A អាចទទួលបានត្រឹមតែ 10000 $ ប៉ុណ្ណោះ (មិនមែន 20000$ ទេ)។

# និយមន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

【ភាពខុសគ្នារវាងកាតព្វកិច្ចដោយសាមគ្គីភាព និងការធានា】

| | ការធានា | កាតព្វកិច្ចដោយសាមគ្គីភាព |
|---|---|---|
| ទំនាក់ទំនងនៃកាតព្វកិច្ចចំបង និង បន្ទាប់បន្សំ | មាន | គ្មាន |
| ភាពបន្ទាប់បន្សំ･ភាពទៅជាមួយ･ភាពបំពេញបន្ថែម | មាន | គ្មាន |
| ទំនាក់ទំនងនៃការទាមទារសំណង | អ្នកធានាអាចទាមទារសំណងពីកូនបំណុលដែលមានកាតព្វកិច្ចចម្បង | អាចទាមទារសុំណងទៅកូនបំណុលផ្សេងទៀតតាមចំនែកដែលបានទទួលបន្ទុក |

# និយមន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព

【ចំណែកនៃបន្ទុក】




ចំពោះកាតព្វកិច្ចដោយសាមគ្គីភាព កូនបំណុលដោយសាមគ្គីភាពនីមួយៗមានករណីយកិច្ចសងបំណុលទាំងអស់ចំពោះម្ចាស់បំណុល ប៉ុន្តែ កូនបំណុលដោយសាមគ្គីភាពអាចកំណត់អំពីចំណែកដែលត្រូវទទួលបន្ទុក (ចំណែកនៃបន្ទុក) ចុងក្រោយរវាងគ្នាបាន។ ភាគនៃបន្ទុកត្រូវសន្មតថាស្មើគ្នា បើសិនជាគ្មានការព្រមព្រៀងពិសេស (មាត្រា ៩២២ កថា ៥)។

# ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

# ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព




មាត្រា៩២២

១ ក្រៅពីករណីដែលមានបញ្ញត្តិនៅក្នុងច្បាប់ កាតព្វកិច្ចដោយសាមគ្គីភាពត្រូវបានបង្កើតឡើង ដោយការព្រមព្រៀង ដោយជាក់លាក់ ឬ ដោយតុណ្ហីភាព រវាងម្ចាស់បំណុល និង កូនបំណុលច្រើននាក់ដែលឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមក ត្រូវបានទទួលស្គាល់។

២ ការព្រមព្រៀងដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ អាចធ្វើឡើងរវាងម្ចាស់បំណុល និង កូនបំណុលនីមួយៗ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់។

# ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

【ការបង្កើតដោយការព្រមព្រៀង】




ការព្រមព្រៀងឲ្យបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព
＝①ការព្រមព្រៀងបង្កើតឲ្យមានកាតព្វកិច្ច(កិច្ចសន្យាខ្ចីបរិភោគជាដើម)
＋②ការសន្យាអំពីសាមគ្គីភាព

# ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

【ការបង្កើតដោយបញ្ញត្តិច្បាប់】

(ខ)មាត្រា975(ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច)

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍

ខ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងទៀត ដែលប្តី ឬ ប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខអក្សរ ពីប្រពន្ធ ឬ ប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម។

---

មាត្រា៩២២

១ ក្រៅពីករណីដែលមានបញ្ញត្តិនៅក្នុងច្បាប់ កាតព្វកិច្ចដោយសាមគ្គីភាពត្រូវបានបង្កើតឡើង ដោយការព្រមព្រៀង ដោយជាក់លាក់ ឬ ដោយតណ្ហីភាព រវាងម្ចាស់បំណុល និង កូនបំណុលច្រើននាក់ដែលឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមក ត្រូវបានទទួលស្គាល់។

# ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

**【មោឃភាព និង ការលុបចោលចំពោះកូនបំណុល】**




មាត្រា៩២៣

ទោះបីជាមានមូលហេតុនៃមោឃភាព ឬ ការលុបចោលសកម្មភាព ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ក៏ដោយ ក៏ការណ៍នេះមិនមានឥទ្ធិពលដល់អានុភាពនៃកាតព្វកិច្ចរបស់កូនបំណុលផ្សេងទៀតឡើយ។

# ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព

**【ការលើកលែងសាមគ្គីភាព】**




**※A អាចយកប្រាក់សរុបពី B ដល់ E ត្រឹមតែ 10000$ ប៉ុណ្ណោះ ប្រសិនបើកាតព្វកិច្ចដោយសាមគ្គីភាពមានចំនួន 10000$ ។**

មាត្រា៩២២

៣ ម្ចាស់បំណុលអាចលើកលែងសាមគ្គីភាព ចំពោះកូនបំណុលណាមួយបានដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលផ្សេងទៀតបាន។

៤ ក្រោយពេលលើកលែងសាមគ្គីភាព កូនបំណុលដែលបានទទួលការលើកលែងត្រូវទទួលបន្ទុកនូវកាតព្វកិច្ចត្រឹមតែចំនួនប្រាក់ដែលស្មើនឹងបន្ទុកដែលខ្លួនធ្លាប់មានមុនពេលលើកលែង។

៥ ភាគនៃបន្ទុករបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពនីមួយៗត្រូវបានសន្មតថាស្មើគ្នា។

# អានុភាពនៃហេតុដែលកើតឡើងចំពោះ កូនបំណុលដែលមានកាតព្វកិច្ចដោយ សាមគ្គីភាពណាម្នាក់

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ហេតុដែលផ្អាកអាជ្ញាយុកាល】




---

មាត្រា៩២៤

ការទាមទារឲ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់អនុវត្ត និង ហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត ដែលកើតឡើងដោយចំពោះកូនបំណុលនោះ ត្រូវមានអានុភាពចំពោះកូនបំណុលផ្សេងទៀតផងដែរ។

# ※អំពីអាជ្ញាយុកាល

【(រលត់)អាជ្ញាយុកាលគឺជា】

មាត្រា 480

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់។

មាត្រា 481

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន។

មាត្រា 482

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង។

# ※អំពីអាជ្ញាយុកាល

**【ការផ្អាកអាជ្ញាយុកាលគឺជា】**

ប្តឹងទាមទារឲ្យសងប្រាក់

**A** → **B**

(អ្នកឲ្យខ្ចី) (អ្នកខ្ចី)

①ដំណើរការនៃអាជ្ញាយុកាលឈប់

＋

②អំឡុងពេលដែលបានដំណើរការពីមុនក្លាយជា 0

---

មាត្រា 489

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ត្រូវផ្អាកក្នុងករណីដូចតទៅ:

ក ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល។

ខ សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងរក្សាការពារ។

គ ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬ វិធីផ្សេង។

# ※អំពីអាជ្ញាយុកាល

## 【ការលើកឡើងនូវអាជ្ញាយុកាល】

**A** ·········▶ **B**

**លើកឡើងនូវអាជ្ញាយុកាល**
⇒កាតព្វកិច្ចរលត់

(អ្នកឲ្យខ្ចី) (អ្នកខ្ចី)

---

មាត្រា 486

១ តុលាការមិនអាចសម្រេចសេចក្ដីដោយយកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលបានឡើយ លើកលែងតែភាគីបានលើកឡើងនូវអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលនោះ។

២ ក្រៅពីកូនបំណុល មានតែកូនបំណុលដោយសាមគ្គីភាព អ្នកធានា អ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម ដែលបានកំណត់ក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម) នៃក្រមនេះ និង បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងការលើកឡើងនូវអាជ្ញាយុកាលទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលបាន។

៣ ប្រសិនបើកូនបំណុលលើកឡើងនូវអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល តតិយជនក៏នឹងទទួលផលប្រយោជន៍នៃអាជ្ញាយុកាលនេះដែរ។ ប្រសិនបើអ្នកដែលមិនមែនជាកូនបំណុល តែមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាលបានលើកឡើងនូវអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលនេះ អានុភាពនៃការលើកឡើងនេះ កើតឡើងតែរវាងម្ចាស់បំណុល និង អ្នកដែលលើកឡើងនូវអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលប៉ុណ្ណោះ។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ហេតុដែលផ្អាកអាជ្ញាយុកាល】




មាត្រា៩២៤

ការទាមទារឲ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់អនុវត្ត និង ហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត ដែលកើតឡើងដោយចំពោះកូនបំណុលនោះ ត្រូវមានអានុភាពចំពោះកូនបំណុលផ្សេងទៀតផងដែរ។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ការសង】




មាត្រា៩២៥

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ បានសង ឬ សងដោយវត្ថុជំនួស ឬ តម្កល់ អានុភាពនៃការរំលត់កាតព្វកិច្ចដែលបានកើតឡើងដោយការណ៍នោះ ត្រូវមានចំពោះកូនបំណុលផ្សេងទៀតផងដែរ។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ការទូទាត់】




មាត្រា៩២៦

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់មានសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ហើយកូនបំណុលនោះបានលើកឡើងនូវការទូទាត់ សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់។

# ※ការទូទាត់គឺជា

**នៅពេលដែល A មានសិទ្ធិលើបំណុលចំពោះ B ហើយ B ក៏មានសិទ្ធិលើបំណុលចំពោះ A នោះកាតព្វកិច្ចរវាងគ្នានេះនឹងត្រូវរលត់ទៅតាមទំហំដោយការបង្ហាញឆន្ទៈរបស់ A ឬ B។**

---

មាត្រា 464

១ ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ដោយយកចំនួនប្រាក់ស្មើគ្នាដោយបង្ហាញឆន្ទៈឯកតោភាគី។

មាត្រា 465

១ ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាង ទៅភាគីម្ខាងទៀត។

# ※ការទូទាត់គឺជា




---

មាត្រា 464
១ ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ដោយយកចំនួនប្រាក់ស្មើគ្នាដោយបង្ហាញឆន្ទៈឯកតោភាគី។

មាត្រា 465
១ ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាង ទៅភាគីម្ខាងទៀត។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ការទូទាត់】




---

មាត្រា៩២៦

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់មានសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ហើយកូនបំណុលនោះបានលើកឡើងនូវការទូទាត់ សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ការទូទាត់】




មាត្រា៩២៦

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់មានសិទ្ធិលើបំណុលចំពោះម្ចាស់បំណុល ហើយកូនបំណុលនោះបានលើកឡើងនូវការទូទាត់ សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់។

២ នៅពេលដែលកូនបំណុលដែលមានសិទ្ធិលើបំណុលដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះ មិនទាន់លើកឡើងនូវការទូទាត់ កូនបំណុលផ្សេងទៀតអាចបដិសេធការសង ចំពោះបន្ទុករបស់ខ្លួនបាន។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【នវកម្ម】




មាត្រា៤២៧

ក្នុងករណីដែលនវកម្មត្រូវបានធ្វើឡើង រវាងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ និង ម្ចាស់បំណុល សិទ្ធិលើបំណុលត្រូវរលត់ សម្រាប់ផលប្រយោជន៍របស់កូនបំណុលទាំងអស់។

មាត្រា 476

១ នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់កាតព្វកិច្ចដើម និង បង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ។

២ នៅពេលកិច្ចសន្យានវកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះបង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរលត់។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ព្យាកុលភាព】




មាត្រា៤២៨

ក្នុងករណីដែលព្យាកុលភាពបានកើតឡើង រវាងកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ និងម្ចាស់បំណុល កូនបំណុលនោះត្រូវបានចាត់ទុកថា បានសង។

មាត្រា 479

១ ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរលត់ដោយព្យាកុលភាព។

២ សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយព្យាកុលភាពឡើយ។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ការលើកលែង】




---

មាត្រា៩២៩

១ ការលើកលែងកាតព្វកិច្ចទាំងអស់ដែលបានធ្វើឡើង ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ ត្រូវមានអានុភាពចំពោះតែបន្ទុករបស់កូនបំណុលនោះសម្រាប់ផលប្រយោជន៍របស់កូនបំណុលផ្សេងទៀត។

២ ក្នុងករណីដែលការលើកលែង បានធ្វើឡើងចំពោះតែកាតព្វកិច្ចមួយភាគ ចំពោះកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ អានុភាពនៃការលើកលែងចំពោះកូនបំណុលផ្សេងទៀត ត្រូវកើតឡើង តាមសមាមាត្រនៃចំនួនទឹកប្រាក់ ក្នុងករណីដែលមានការលើកលែងកាតព្វកិច្ចទាំងអស់។

មាត្រា 473

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវរលត់។

មាត្រា 474

ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់




មាត្រា៩៣០

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បើលើកឡើងនូវអាជ្ញាយុកាលដែលត្រូវបានសម្រេចចំពោះខ្លួន កូនបំណុលផ្សេងទៀតក៏ត្រូវរួចផុតពីកាតព្វកិច្ច ត្រឹមបន្ទុករបស់កូនបំណុលដែលបានលើកឡើងនូវអាជ្ញាយុកាលនោះ។

២ ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងពេលដែលអាជ្ញាយុកាលត្រូវបានសម្រេច តែមិនទាន់ត្រូវបានលើកឡើង កូនបំណុលផ្សេងទៀតអាចលើកឡើងនូវអាជ្ញាយុកាលនោះ ចំពោះបន្ទុករបស់កូនបំណុលដែលអាចលើកឡើងនូវអាជ្ញាយុកាលនោះ។

# អានុភាពនៃហេតុដែលកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់

【ហេតុផ្សេងទៀត】




---

មាត្រា៩៣១

ហេតុដែលបានកើតឡើងចំពោះកូនបំណុល ដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ មិនត្រូវមានអានុភាព ចំពោះកូនបំណុលផ្សេងទៀតឡើយ លើកលែងតែហេតុដែលបានកំណត់ពីមាត្រា ៩២៤ (អានុភាពដាច់ខាតនៃការទាមទារ និង ហេតុដែលផ្អាកអាជ្ញាយុកាលផ្សេងទៀត) ដល់មាត្រា ៩៣០ (អានុភាពដាច់ខាតនៃអាជ្ញាយុកាល) ខាងលើនេះ។

# ការទាមទារសំណង

# ការទាមទារសំណង




មាត្រា៩៣២

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឲ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតកិច្ច កូនបំណុលនោះត្រូវទទួលសិទ្ធិទាមទារសំណងពីកូនបំណុលផ្សេងទៀត ចំពោះបន្ទុករៀងៗខ្លួន។ ក្នុងករណីដែលការសង ឬ ចំណាយផ្សេងទៀតរបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីណាម្នាក់ មានចំពោះតែកាតព្វកិច្ចមួយភាគ ហើយកូនបំណុលនោះ និង កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតបានទទួលការរួចផុតពីកាតព្វកិច្ច តាមកម្រិតនៃភាគនោះ កូនបំណុលនោះអាចទាមទារសំណង តាមសមាមាត្រនៃបន្ទុករបស់កូនបំណុលផ្សេងទៀតបាន។

២ ការទាមទារសំណងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបាន ដោយរាប់បញ្ចូលការប្រាក់ដែលច្បាប់បានកំណត់ ដោយគិតពីថ្ងៃរួចផុតពីកាតព្វកិច្ចដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន និង សោហ៊ុយឬការខូចខាតផ្សេងទៀតដែលមិនអាចជៀសវៀងបាន។

# ការទាមទារសំណង




មាត្រា៩៣២

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឲ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតកិច្ច កូនបំណុលនោះត្រូវទទួលសិទ្ធិទាមទារសំណងពីកូនបំណុលផ្សេងទៀត ចំពោះបន្ទុករៀងៗខ្លួន។ ក្នុងករណីដែលការសង ឬ ចំណាយផ្សេងទៀតរបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីណាម្នាក់ មានចំពោះតែកាតព្វកិច្ចមួយភាគ ហើយកូនបំណុលនោះ និង កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតបានទទួលការរួចផុតពីកាតព្វកិច្ច តាមកម្រិតនៃភាគនោះ កូនបំណុលនោះអាចទាមទារសំណង តាមសមាមាត្រនៃបន្ទុករបស់កូនបំណុលផ្សេងទៀតបាន។

២ ការទាមទារសំណងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបាន ដោយរាប់បញ្ចូលការប្រាក់ដែលច្បាប់បានកំណត់ ដោយគិតពីថ្ងៃរួចផុតពីកាតព្វកិច្ចដោយបានសង ឬ បានចេញចំណាយផ្សេងទៀតរបស់ខ្លួន និង សោហ៊ុយឬការខូចខាតផ្សេងទៀតដែលមិនអាចជៀសវៀងបាន។

# ការទាមទារសំណង

【វិធីទាមទារសំណង】

ជូនដំណឹងទៅកូនបំណុលដោយសាមគ្គីភាពផ្សេងទៀត មុនពេលសង

↓ មូលហេតុៈ ប្រហែលជាកូនបំណុលដោយសាមគ្គីភាពផ្សេងទៀតមានហេតុដែលអាចតតាំងចំពោះម្ចាស់បំណុល

សងទៅម្ចាស់បំណុល

↓

ជូនដំណឹងទៅកូនបំណុលដោយសាមគ្គីភាពផ្សេងទៀត ក្រោយពេលសង

↓ មូលហេតុៈជៀសវាងការសងជាន់គ្នាដោយកូនបំណុលដោយសាមគ្គីភាពផ្សេងទៀត

ទាមទារសំណងពីកូនបំណុលដោយសាមគ្គីភាពផ្សេងទៀត

# ការទាមទារសំណង

【ប្រសិនបើភ្លេចជូនដំណឹងជាមុន】




មាត្រា៩៣៣ ការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌដើម្បីទាមទារសំណង

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ បានបំពេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយបានធ្វើឲ្យកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀតរួចផុតពីកាតព្វកិច្ចដោយពុំបានជូនដំណឹងទៅឲ្យកូនបំណុលផ្សេងទៀតថា ខ្លួនបានទទួលការទាមទារពីម្ចាស់បំណុល បើកូនបំណុលផ្សេងទៀតណាមួយ មានហេតុដែលអាចតតាំងចំពោះការទាមទារសំណងពីកូនបំណុលដែលបានទទួលការរួចផុត ដោយបានសង ឬ ចេញចំណាយបាន។ ប៉ុន្តែ បើហេតុដែលអាចតតាំងជាការទូទាត់ កូនបំណុលដែលត្រូវបានតតាំង អាចទាមទារឲ្យម្ចាស់បំណុលអនុវត្តកាតព្វកិច្ចដែលនឹងត្រូវរលត់ ដោយការទូទាត់។

# ការទាមទារសំណង




មាត្រា៩៣៣ ការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌដើម្បីទាមទារសំណង

២ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់បានធ្វើឲ្យខ្លួន និង កូនបំណុលផ្សេងទៀត រួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន តែមិនបានជូនដំណឹងអំពីហេតុនោះ ទៅកូនបំណុលផ្សេងទៀត បើកូនបំណុលផ្សេងទៀតបានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ដោយមិនបានដឹងអំពីមូលហេតុនោះ កូនបំណុលដែលបានរួចផុតពីកាតព្វកិច្ចពេលក្រោយនោះ អាចចាត់ទុកថា ការសង ឬ សកម្មភាពផ្សេងទៀតរបស់ខ្លួនដែលធ្វើឲ្យរួចផុតពីកាតព្វកិច្ចនោះ មានសុពលភាព។

៣ ក្នុងករណីដែលការសង ឬ សកម្មភាពដែលធ្វើឲ្យរួចពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀតរបស់ខ្លួនត្រូវបានធ្វើឡើង ដោយកូនបំណុលច្រើន ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ហើយបើការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនបានធ្វើឡើង នោះការសង ឬ សកម្មភាពដែលឲ្យរួចផុតពីកាតព្វកិច្ចដោយចេញចំណាយផ្សេងទៀតរបស់ខ្លួន ដែលកូនបំណុលណា បានធ្វើមុន ត្រូវចាត់ទុកថា មានសុពលភាព។

# ការទាមទារសំណង

【ការទាមទារសំណងក្នុងករណីដែលមានអ្នកជាអសាធនីយក្នុងការសង】




មាត្រា៩៣៤

បើមានអ្នកដែលស្ថិតនៅក្នុងស្ថានភាពអសាធនីយ៍ក្នុងការសង ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព ផ្នែកដែលមិនអាចសងបាននោះ ត្រូវជាបន្ទុករបស់អ្នកដែលទាមទារសំណង និង អ្នកដែលជាសាធនីយ៍ តាមសមាមាត្រនៃបន្ទុករៀងៗខ្លួន។ ប៉ុន្តែ បើអ្នកដែលទាមទារសំណងមានកំហុស អ្នកនោះមិនអាចទាមទារឲ្យកូនបំណុលផ្សេងទៀតទទួលបន្ទុកបានឡើយ។

# ការទាមទារសំណង

【ការលើកលែងសាមគ្គីភាព និង អ្នកដែលជាអាសាធនីយ៍】

※សន្មតថាកាតព្វកិច្ចដោយសាមគ្គីភាពពីដំបូងចំនួន៩០០០$




មាត្រា៤៣៥

ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាព បានទទួលការលើកលែងសាមគ្គីភាព បើមានអ្នកដែលជាអសាធនីយ៍ក្នុងការសង ក្នុងចំណោមកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពផ្សេងទៀត ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវផ្នែកដែលអ្នកដែលទទួលការលើកលែងសាមគ្គីភាពត្រូវទទួលបន្ទុក ចំពោះផ្នែកដែលជាអសាធនីយ៍នោះមិនអាចឆ្លើយតបនឹងការទាមទារសំណងបាន។

# ឧបាទេសកម្មដោយការសទ

# ឧបាទេសកម្មដោយការសង




មាត្រា៩៣៦

១ ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពណាម្នាក់ទទួលសិទ្ធិទាមទារសំណង ចំពោះកូនបំណុលផ្សេងទៀត អ្នកទាមទារសំណង ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្មចំពោះសិទ្ធិលើបំណុលដែលម្ចាស់បំណុលធ្លាប់មានចំពោះកូនបំណុលផ្សេងទៀត និង សិទ្ធិប្រាតិភោគដើម្បីធានាសិទ្ធិលើបំណុលនោះ ក្នុងទំហំនៃការទាមទារសំណងនោះ។

២ ក្រៅពីបញ្ញត្តិនៃមាត្រានេះ បញ្ញត្តិនៃកថាភាគទី៤ (ឧបាទេសកម្មដោយការសង) ផ្នែកទី១ ជំពូកទី៧ នៃគន្ថីទី៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបាទេសកម្មរបស់អ្នកទាមទារសំណង។

# បែបយ៉ាងផ្សេងទៀតនៃការតព្វកិច្ចដែលមានកូនបំណុលច្រើននាក់

# បែបយ៉ាងផ្សេងទៀតនៃកាតព្វកិច្ចដែលមានកូនបំណុលច្រើននាក់




មាត្រា៩៣៧

១ បញ្ញត្តិនៃមាត្រា ៩២១ (អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព) នៃក្រមនេះត្រូវយកមកអនុវត្តដោយគ្នាផងដែរ ចំពោះករណីដែលកូនបំណុលច្រើននាក់ទទួលកាតព្វកិច្ចដែលមានគោលបំណងដូចគ្នា ចំពោះម្ចាស់បំណុលតែម្នាក់ ហើយឆន្ទៈសាមគ្គីភាពរួមគ្នាទៅវិញទៅមក មិនត្រូវបានទទួលស្គាល់រវាងកូនបំណុលទាំងនេះ។ ប៉ុន្តែ ក្នុងករណីដែលតាវកាលិកនៃកាតព្វកិច្ចនោះ អាចបែងចែកបាន ហើយការបែងចែកនោះមិនខូចខាតដល់ផលប្រយោជន៍របស់ម្ចាស់បំណុលនោះ កូនបំណុលនីមួយៗត្រូវទទួលកាតព្វកិច្ចដែលត្រូវបានបែងចែក តាមសមាមាត្រនៃបន្ទុករៀងៗខ្លួន។ បើបន្ទុករបស់កូនបំណុលម្នាក់ៗមិនច្បាស់លាស់ បន្ទុកនោះត្រូវសន្មតថា ស្មើៗគ្នា។

២ ក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី១ នៃកថាខណ្ឌទី១ ខាងលើនេះ ហេតុដែលបានកើតឡើងចំពោះកូនបំណុលម្នាក់ មិនត្រូវមានឥទ្ធិពលដល់កូនបំណុលផ្សេងទៀត លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ៩២៥ (អានុភាពដាច់ខាតនៃការសង ជាអាទិ៍) និង កថាខណ្ឌទី១ នៃមាត្រា ៩២៦ (អានុភាពដាច់ខាតនៃការទូទាត់) ខាងលើនេះ។

៣ ក្នុងករណីដែលកូនបំណុលណាម្នាក់ ក្នុងចំណោមកូនបំណុលដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី១ នៃកថាខណ្ឌទី១ ខាងលើនេះ បានរួចផុតពីកាតព្វកិច្ច ដោយបានសង ឬ ចេញចំណាយផ្សេងទៀតរបស់ខ្លួន ហើយធ្វើឲ្យកូនបំណុលផ្សេងទៀតរួចផុតពីកាតព្វកិច្ច បើមានភាពចាំបាច់ត្រូវរក្សាសមភាពរវាងកូនបំណុលដែលបានចេញចំណាយ និង កូនបំណុលផ្សេងទៀត អ្នកដែលបានចេញចំណាយ ត្រូវទទួលសិទ្ធិទាមទារសំណងចំពោះកូនបំណុលផ្សេងទៀត ក្នុងកម្រិតដែលអាចធ្វើឲ្យមានសមភាពនោះ។

# សូមអរគុណ